**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ**
**នីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ**
(កាំកុងត្រូល)

លេខ: ៤៦៣ អ.គពទ
ឈង

# របាយការណ៍
## ស្តីពីសកម្មភាពការងារ របស់អគ្គនាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ប្រចាំខែមិថុនា ឆ្នាំ២០១៨ និងទិសដៅអនុវត្តខែបន្ទាប់

ដើម្បីកសាងបាននូវលទ្ធភាព នៃការប្រកួតប្រជែងក្នុងពាណិជ្ជកម្ម និងបំពេញបាននូវគោលបំណងនៃកិច្ចសម្រួលពាណិជ្ជកម្ម លើកកម្ពស់ផលិតកម្ម អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) មានតួនាទីធានាគុណភាពនៃផលិតផលឱ្យសមស្របតាមស្តង់ដារ និងតម្រូវការរបស់ទីផ្សារ ការការពារកម្មសិទ្ធិបញ្ញា ការទប់ស្កាត់ការក្លែងបន្លំ ធានាគុណភាពឱ្យការនាំចេញ ក៏ដូចជាការប្រើប្រាស់ក្នុងស្រុក ជៀសវាងផលប៉ះពាល់ដល់សុវត្ថិភាព និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ក្នុងខែមិថុនា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានកាំកុងត្រូល បានខិតខំអនុវត្តភារកិច្ចរបស់ខ្លួនសម្រេចបានលទ្ធផលដូចខាងក្រោម ៖

### ១. ការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន

គោលបំណងទប់ស្កាត់ការនាំចូល-នាំចេញទំនិញពុំសមស្រប តាមបញ្ញត្តិបច្ចេកទេស ពាក់ព័ន្ធនឹងគុណភាពសុវត្ថិភាពផលិតផល និងគោលនយោបាយពាណិជ្ជកម្ម ក្នុងទិសដៅរួមគឺ ការពារអ្នកប្រើ ការពារការធ្វើពាណិជ្ជកម្មឱ្យមានសមធម៌ និងការពារកេរ្តិ៍ឈ្មោះផលិតផលកម្ពុជា នៅលើទីផ្សារអន្តរជាតិ ។

អគ្គនាយកដ្ឋានកាំកុងត្រូល បានដំណើរការត្រួតពិនិត្យទំនិញនាំចេញ-នាំចូលតាមច្រកទ្វារព្រំដែនដោយមានការគាំទ្រដោយរថយន្តពិសោធន៍ចល័ត ធ្វើការវិភាគផលិតផលទំនិញនៅច្រកទ្វារព្រំដែនផ្ទាល់ និងយកគំរូបញ្ជូនមក វិភាគនៅមន្ទីរពិសោធន៍របស់អគ្គនាយកដ្ឋានផងដែរ ។

<u>**លទ្ធផល**</u> :

- បានរកឃើញ ឃាត់ទុក ឬកំទេចចោល ផលិតផលខូចគុណភាពមួយចំនួនដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| + សាច់-ឆ្អឹងមាន់ | ចំនួន | ៤៤០ គីឡូក្រាម | នៅខេត្តបាត់ដំបង |
| + កំទេចនំ-កំទេចមី | - | ៣៩៥ គីឡូក្រាម | នៅខេត្តបាត់ដំបង |
| + អំបិលគ្មានអ៊ីយ៉ូដ | - | ៣៥០ គីឡូក្រាម | នៅខេត្តបន្ទាយមានជ័យ |

### ២. ការត្រួតពិនិត្យពាណិជ្ជកម្ម (ភាគីទី ៣)

ក្រៅពីការអនុវត្តន៍សកម្មភាពត្រួតពិនិត្យជាលក្ខណៈផ្លូវច្បាប់ អគ្គនាយកដ្ឋានត្រូវបានទទួលអាណត្តិ

ផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មលក្ខណៈជាភាគីទី៣ ដែលជាសកម្មភាពមួយ បំពេញឱ្យតម្រូវការក្នុងកិច្ចសម្រួលពាណិជ្ជកម្មផងដែរ ។

**លទ្ធផល**: អគ្គនាយកដ្ឋានកាំកុងត្រូល ទទួលសំណើរបស់អតិថិជនឱ្យត្រួតពិនិត្យទំនិញ ដែលជាការស្នើសុំរបស់អង្គការ World Food Programme បានចំនួន ០២ សំណើ ។

### ៣. ការឃ្លាំពិនិត្យទីផ្សារ

ការឃ្លាំពិនិត្យទីផ្សារ គឺជាកិច្ចការបំរើឱ្យគោលដៅអនុវត្តច្បាប់ ទប់ស្កាត់ការធ្វើចរាចរណ៍ផលិតផលខ្វះភាពអនុលោមតាមបញ្ញត្តិ ឬបទដ្ឋានបច្ចេកទេស ដែលជាការបង្កគ្រោះដល់សុខភាពមនុស្ស រួមចំណែកបង្កើនគុណភាព សុវត្ថិភាពផលិតផលផលិតក្នុងស្រុក និងកាត់បន្ថយការនាំចូល ។

ក្រៅពីបញ្ហាគុណភាព ការបង្ក្រាបការក្លែងបន្លំតាមគ្រប់ទិដ្ឋភាព ក៏ត្រូវបានដំណើរការជាមួយគ្នាដែរ សំដៅការពារផលប្រយោជន៍អ្នកប្រើ និងជម្រុញឱ្យការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌ ។

កម្មវិធីដែលត្រូវបានអនុវត្តក្នុងការត្រួតពិនិត្យមាន៖

- ធ្វើតេស្តបឋមរកវត្តមានសារធាតុគីមីលើផលិតផលស្រស់ និងកែច្នៃមួយចំនួន ព្រមទាំងយកគំរូមកវិភាគនៅមន្ទីរពិសោធន៍ផងដែរ ។

- ត្រួតពិនិត្យសុពលភាពនៃការប្រើប្រាស់ (ថ្ងៃ-ខែ-ឆ្នាំផលិត ឬថ្ងៃ-ខែ-ឆ្នាំផុតកំណត់ប្រើប្រាស់) និងស្លាកសញ្ញាលើសំបកវេចខ្ចប់ ។

- ត្រួតពិនិត្យ និងអប់រំអំពីអនាម័យ និងការរៀបចំដាក់លក់តាមប្រភេទផលិតផល ។

- ត្រួតពិនិត្យកម្រិតជាតិអ៊ីយ៉ូដដែលមាននៅក្នុងអំបិល និងណែនាំអំពីសារៈសំខាន់ក្នុងការប្រើប្រាស់អំបិលមានជាតិអ៊ីយ៉ូដ ។

- ត្រួតពិនិត្យ និងធ្វើតេស្តបឋមរកវត្តមានសារធាតុគីមី Sodium Hydrosulfite និង Sulfite លើផលិតផលស្ករត្នោត ។

កិច្ចការនេះ ត្រូវបានគាំទ្រដោយរថយន្តពិសោធន៍ចល័ត ធ្វើការវិភាគផលិតផលទំនិញនៅទីផ្សារដោយទទួលបានលទ្ធផលភ្លាមៗ និងបញ្ជូនគំរូមកវិភាគនៅមន្ទីរពិសោធន៍របស់អគ្គនាយកដ្ឋានផងដែរ ។

**លទ្ធផល** :

- មន្ត្រីកាំកុងត្រូលនៅតាមបណ្តាខេត្ត-រាជធានី បានត្រួតពិនិត្យសុវត្ថិភាពម្ហូបអាហារតាមបណ្តាទីផ្សារនានាទូទាំងប្រទេសបានចំនួន ១៨៣ ផ្សារ ដោយបានដកហូតទំនិញដែលមានភាពមិនប្រក្រតី (ទំនិញក្លែងក្លាយ, ខូចគុណភាព, ផុតកំណត់រយៈពេល ប្រើប្រាស់ ...ល...) មកកំទេចចោលដែលរួមមាន ៖

| | | | | | | |
|---|---|---|---|---|---|---|
| + នំ-ស្ករគ្រាប់ | ចំនួន | ៣៨១ | កញ្ចប់ | = | ១៦១.៨៧ | គីឡូក្រាម |
| + មីកញ្ចប់/កំប៉ុង | - | ៣៧ | កញ្ចប់/កំប៉ុង | = | ២.៩២ | គីឡូក្រាម |
| + កំទេចមី | - | ៧.៦០ | គីឡូក្រាម | | | |
| + សរសៃគុយទាវ-មី | - | ៥.៦៩ | គីឡូក្រាម | | | |
| + ត្រីខកំប៉ុង | - | ២៨ | កំប៉ុង | = | ៥.១៨ | គីឡូក្រាម |
| + ប្រហិត | - | ១០.០០ | គីឡូក្រាម | | | |
| + ទឹកដោះគោខាប់ | - | ៣២ | កំប៉ុង | = | ៩.១២ | គីឡូក្រាម |
| + ទឹកដោះគោរាវ | - | ១៧៦ | ប្រអប់/កំប៉ុង | = | ៤៨.២៥ | លីត្រ |
| + ម្សៅស៊ុប | - | ៩៦ | កញ្ចប់ | = | ២.៦៨ | គីឡូក្រាម |

| | | | | | | |
|---|---|---|---|---|---|---|
| + បង្អែម(លត-បាញ់ឌុក-នំស្លឹកស្រស់) | - | ១៣៧.២០ | គីឡូក្រាម | | | |
| + ចាហួយ | - | ១២៨ | កញ្ចប់ | = | ១៨២.៥៨ | គីឡូក្រាម |
| + ទឹកត្រី-ទឹកស៊ីអ៊ីវ-ទឹកម្ទេស-ទឹកខ្មេះ | - | ១៦៨ | ដប | = | ៧៩.៨០ | លីត្រ |
| + ផ្លែឈើក្រៀម | - | ១៨ | កញ្ចប់ | = | ៣.២៥ | គីឡូក្រាម |
| + ប្រេងឆា | - | ៣៥ | ដប | = | ១២.២០ | គីឡូក្រាម |
| + សណ្តែកកំប៉ុង | - | ១៨ | កំប៉ុង | = | ៦.៧៧ | គីឡូក្រាម |
| + បន្លែស្រស់ | - | ១៣ | គីឡូក្រាម | | | |
| + បន្លែជ្រក់ | - | ៤ | គីឡូក្រាម | | | |
| + បន្លែ-ផ្លែឈើកំប៉ុង | - | ២២ | កំប៉ុង | = | ៦.៦០ | គីឡូក្រាម |
| + ភេសជ្ជៈមាន ឬគ្មានជាតិសុរា | - | ១,៩៩៧ | ដប /កំប៉ុង | = | ១,១៥០.៩៧ | លីត្រ |
| + ឡេលាបស្បែក | - | ១ | ធុង | = | ៥.០០ | គីឡូក្រាម |

- ដោយយោងលទ្ធផលវិភាគ ទៅលើផលិតផលនំស្លឹកស្រស់ នំបាញ់ឌុក លត និងនំស្រួយ ដែលដាក់លក់នៅលើទីផ្សារ មានផ្ទុកសារធាតុគីមីបូរ៉ាក់ មន្ត្រីកាំកុងត្រូលបានកោះអញ្ជើញម្ចាស់សិប្បកម្មផលិតនំខាងលើចំនួន ០៧ នាក់ ( ០៧សិប្បកម្ម) មកណែនាំ និងធ្វើកិច្ចសន្យាបញ្ឈប់ការប្រើប្រាស់សារធាតុគីមីហាមឃាត់លើផលិតផលបន្តទៀត បើពុំនោះទេ អគ្គនាយកដ្ឋានកាំកុងត្រូល នឹងអនុវត្តវិធានការណ៍ច្បាប់ ។

## ៤.ការបង្រ្កាបការក្លែងបន្លំ

ការបង្រ្កាបការក្លែងបន្លំ ជាភារកិច្ចមួយដ៏សំខាន់ផងដែរ ដើម្បីការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ជៀសវាងការភ័ន្តច្រឡំក្នុងការទិញផលិតផលដែលពុំមានគុណភាពយកមកប្រើប្រាស់ ដែលអាចធ្វើអោយខាតបង់ផលប្រយោជន៍សេដ្ឋកិច្ច (និងអាចប៉ះពាល់ដល់សុខភាព) និងការពារដល់អាជីវកម្ម ពាណិជ្ជកម្មប្រកបដោយសមធម៌ ។

<u>**លទ្ធផល**</u> :

- បានចុះត្រួតពិនិត្យគុណភាពកម្រិតសន្ទស្សន៍អុកតាន (Octane) និងបរិមាណរង្វាស់រង្វាល់ នៅស្ថានីយប្រេងឥន្ធនៈចំនួន២៩ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ដោយបានរកឃើញស្ថានីយចំនួន ០៧ បានដាក់លក់ប្រេងមានកម្រិតលំអៀងទាំងផ្នែកកម្រិតអុកតាន និងបរិមាណ និងស្ថានីយចំនួន១២ លក់ប្រេងជូនអតិថិជនមានកម្រិតលំអៀង (បាត់បង់) ផ្នែកបរិមាណ ។ អគ្គនាយកដ្ឋានកាំកុងត្រូល បានអនុវត្តតាមនីតិវិធី ចំពោះស្ថានីយដែលត្រូវបានរកឃើញមានភាពមិនប្រក្រតីខាងលើ ។

- បានចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យទីតាំងស្តុក និងចែកចាយផលិតផលក្លែងក្លាយចំនួន ០២ទីតាំងនៅរាជធានីភ្នំពេញ គឺ៖ ទីតាំងស្តុកគ្រឿងសម្អាងមួយកន្លែង ដោយរកឃើញគ្រឿងសម្អាងចម្រុះពុំមានច្បាប់អនុញ្ញាតចំនួន ១,១៨៣គីឡូក្រាម និងទីតាំងស្តុកបារី ៥៥៥ ក្លែងក្លាយមួយកន្លែង រកឃើញបារី ៥៥៥ ក្លែងក្លាយ ១៧សុង និង ០៤ កញ្ចប់ ។ វត្ថុតាង ត្រូវបានដកហូតមករក្សាទុកដើម្បីចាត់ចែងតាមនីតិវិធី ។

- បានចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យសិប្បកម្មចំនួន ០៥ នៅរាជធានីភ្នំពេញគឺ ៖ សិប្បកម្មផលិតតៅហ៊ូ ០១កន្លែង និងសិប្បកម្មបំពងបាយក្តាំងចំនួន ០៤កន្លែង ។ មន្ត្រីកាំកុងត្រូលបានដកយកគំរូមួយចំនួន បញ្ជូនទៅវិភាគនៅមន្ទីរពិសោធន៍អគ្គនាយកដ្ឋានកាំកុងត្រូល ដើម្បីបញ្ជាក់អំពីភាពសមស្របរបស់ផលិតផល។

### ៥. ការលើកកម្ពស់ការយល់ដឹងសាធារណៈ

ដើម្បីជំរុញឱ្យប្រជាពលរដ្ឋ ចេះប្រើប្រាស់ម្ហូបអាហារ ប្រកបដោយសុវត្ថិភាព និងមានអនាម័យត្រឹមត្រូវ អគ្គនាយកដ្ឋានកាំកុងត្រូលបានអនុវត្តកម្មវិធីអប់រំ និងណែនាំការយល់ដឹងអំពីអនាម័យ ពាក់ព័ន្ធនឹងផលិតផល (វិធីសាស្រ្តដាក់ស្តែងពាក់ព័ន្ធនឹងការកាន់ប៉ះពាល់, ការរៀបចំទុកដាក់តាំងលក់, កន្លែងលក់ ។ល។) និងរបៀបជ្រើសរើសផលិតផលមានគុណភាព សុវត្ថិភាពមកប្រើប្រាស់ ។

<u>លទ្ធផល</u>:

- បានចុះផ្សព្វផ្សាយអំពីសុវត្ថិភាពម្ហូបអាហារដល់សិស្សានុសិស្សបានចំនួន ០៥លើក នៅតាមបណ្តាគ្រឹះស្ថានសិក្សាក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ដោយមានសិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងអាជីវករចូលរួមចំនួន ១,២២៥ នាក់ ។

- បានចុះផ្សព្វផ្សាយអនុក្រឹត្យលេខ១៣៣ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ បានចំនួន ០២លើក នៅរាជធានីភ្នំពេញ។

- បានបិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារដែលមានសុវត្ថិភាពនៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន ៦២៦ ផ្ទាំង ។

### ៦. បញ្ចរទំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points)

បានស្រាវជ្រាវ និងពិនិត្យសេចក្តីជូនដំណឹងអំពីអនាម័យ និងភូតគាមអនាម័យបានចំនួន ៥៣ (ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន ៤៦, ផ្នែកកិច្ចការពារដំណាំចំនួន០៣ និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន ០៤) ពី១៧ ប្រភព ។ សេចក្តីជូនដំណឹងទាំងនោះ ត្រូវបានបញ្ជូនទៅស្ថាប័នឬក្រសួងពាក់ព័ន្ធ(ទាំងស្ថាប័នរដ្ឋ និងឯកជន) ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

### ៧. ការវិភាគគុណភាពទំនិញ

មន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានកាំកុងត្រូល បានធ្វើការត្រួតពិនិត្យ និងវិភាគគុណភាពផលិតផល អំពីចរិតលក្ខណៈផ្នែករូបវន្ត, គីមីសាស្រ្ត, និងផ្នែកមីក្រូជីវសាស្រ្ត ដើម្បីកំណត់អំពីភាពសមស្របរបស់ផលិតផលម្ហូបអាហារ និងមិនមែនម្ហូបអាហារ ។

<u>**លទ្ធផល**</u> : បានធ្វើការវិភាគលើផលិតផលចំនួន ៤២៧ គំរូ ហើយបានរកឃើញផលិតផលចំនួន ១៤ គំរូមិនសមស្របតាមបញ្ញត្តិបច្ចេកទេស ។

ផលិតផលមិនសមស្រប ដែលត្រូវបានរកឃើញ ៖

| | គំរូដែលមិនសមស្រប | ប៉ារ៉ាម៉ែត្រវិភាគ | ចំនួន |
|---|---|---|---|
| ១ | ម្សៅ (ម្សៅស) | សូដ្យូមអ៊ីដ្រូស៊ុលហ្វីត | ១ |
| ២ | មីកបំពង់ស្រស់ | ហ្វ័រម៉ាលីន | ១ |
| ៣ | ប្រេងឆា | Peroxide value, Acid value, and Polar Compound | ៦ |
| ៤ | បង្អែម (បាញ់ឌុក) | បូរ៉ាក់ | ១ |
| ៥ | ចាហួយ | បង់សូអ៊ិចអាស៊ីត | ២ |
| ៦ | សាច់ប៉ាតេ | មីក្រូជីវសាស្រ្ត | ២ |
| ៧ | នំប៉័ងពងទា | មីក្រូជីវសាស្រ្ត | ១ |
| | សរុប | | ១៤ |

## ៨. ការប្រមូលចំណូល

ប្រាក់ចំណូលគឺបានមកពីកំរៃនៃការត្រួតពិនិត្យទំនិញនាំចូល-នាំចេញ និងការវិភាគគុណភាពទំនិញ តាមអត្រាកំណត់ដោយប្រកាសរួម រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ១៦៨៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធ ភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ។ ប្រាក់ចំណូលដែលទទួលបានពីកំរៃសេវាត្រួតពិនិត្យក្នុងខែមិថុនា ឆ្នាំ២០១៨ មាន ៖

| ប្រភេទទំនិញ | តម្លៃទំនិញ (USD) | កំរៃសេវាត្រួតពិនិត្យ (៛) | | ប្រៀបធៀប (៛) |
|---|---|---|---|---|
| | | ខែឧសភាឆ្នាំ ២០១៨ | ខែមិថុនា ឆ្នាំ ២០១៨ | |
| នាំចូល | ១,៤៥៥,២១៨,០៣០ | ៦,៣៨២,៣៤៥,០០០ | ៦,៨៨៣,០៤០,០០០ | ៥០០,៦៩៥,០០០ |
| នាំចេញ | ១,២០៧,៨៧១,៥២៥ | ៣,៦៧៦,៣១០,០០០ | ៤,៨៣៣,៩១៥,០០០ | ១,១៥៧,៦០៥,០០០ |
| **សរុប** | **២,៦៦៣,០៨៩,៥៥៥** | **១០,០៥៨,៦៥៥,០០០** | **១១,៧១៦,៩៥៥,០០០** | **១,៦៥៨,៣០០,០០០** |

ក្នុងខែមិថុនា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានកាំកុងត្រូលរកចំណូលបានចំនួន ១១,៧១៦,៩៥៥,០០០ រៀល បើប្រៀបធៀបជាមួយប្រាក់ចំណូលក្នុងខែឧសភា ឆ្នាំ២០១៨ ដែលមានចំនួន ១០,០៥៨,៦៥៥,០០០រៀល ឃើញកើនឡើងចំនួន ១,៦៥៨,៣០០,០០០រៀល ស្មើ ១៦.៤៩% និងកើនឡើងចំនួន ២,៣៣៨,៦០៣,០០៨ រៀល ស្មើនឹង ២៤.៩៤% បើប្រៀបធៀបជាមួយប្រាក់ចំណូលក្នុងខែមិថុនា ឆ្នាំ ២០១៧ ។

**<u>ទិសដៅអនុវត្តខែបន្ទាប់</u>**

- អនុវត្ត "កម្មវិធីត្រួតពិនិត្យការនាំចូល" ទាំងម្ហូបអាហារ និងផលិតផលមិនមែនម្ហូបអាហារ ដែលមានបញ្ញត្តិគ្រប់គ្រង លើមូលដ្ឋាននៃការគ្រប់គ្រងហានិភ័យ ដោយរួមទាំងការកសាង និងធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មាន ស្តីពីគ្រោះ (Risk Profile ) តាមក្រុមទំនិញ និងធ្វើការវិភាគលទ្ធផលដែលរកឃើញ ។

- ពង្រឹងប្រសិទ្ធភាព "ត្រួតពិនិត្យការនាំចេញ" ពិសេសការត្រួតពិនិត្យផ្នែករដ្ឋបាល លើផលិតផលកាត់ដេរ សំដៅបំពេញនូវលក្ខខណ្ឌតម្រូវអំពីវិធាន GSP/MFN និងលើផលិតផលជាប់កម្រិតកំណត់ផ្សេងៗទៀត ក្នុងក្របខ័ណ្ឌនៃកិច្ចសម្រួលពាណិជ្ជកម្ម ។

- អនុវត្ត "កម្មវិធីឃ្លាំពិនិត្យទីផ្សារ" ក្នុងប្រទេស តាមរយៈការស្រាវជ្រាវនិងវាយតំលៃអំពីគ្រោះ សំដៅជំរុញឱ្យមានភាពសមស្របតាមបញ្ញត្តិបច្ចេកទេស ពាក់ព័ន្ធនឹងម្ហូបអាហារ និងផលិតផលដែលមានបញ្ញត្តិបច្ចេកទេសគ្រប់គ្រង សំដៅលុបបំបាត់រាល់ការលួចប្រើសារធាតុគីមីហាមឃាត់ និងកាត់បន្ថយឱ្យនៅត្រឹមកម្រិតសមស្របនូវសំណល់ថ្នាំសំលាប់សត្វល្អិត លើផលិតផលកសិ-ម្ហូបអាហារសំខាន់ៗ មួយចំនួន ។

- បង្ក្រាបការក្លែងបន្លំពាណិជ្ជកម្មផ្សេងៗ សំដៅការពារផលប្រយោជន៍អ្នកប្រើ ។

- រៀបចំឱ្យមាននីតិវិធីសំរាប់អនុវត្តការងារផ្សេងៗ នៅក្នុងមន្ទីរពិសោធន៍ ជាអាទ៍ នីតិវិធីសំរាប់ធ្វើតេស្ត នីតិវិធីសម្រាប់យកគំរូ និងនីតិវិធីសំរាប់ការងារគ្រប់គ្រង ។

- ធ្វើការវិភាគជាក់ស្តែងតាម Test Kits និងតាមវិធីសាស្រ្តប្រើឧបករណ៍របស់មន្ទីរពិសោធន៍ នូវគំរូម្ហូបអាហារ ជាកិច្ចអនុវត្តកម្មវិធីឃ្លាំពិនិត្យទីផ្សារ ពិនិត្យសហគ្រាសផលិត និងពិនិត្យតាមសំណើពីប្រភពផ្សេងៗ ជាពិសេសម្ចាស់សហគ្រាស (ទាំងផ្នែកមេរោគ គីមី និងរូប) ។

- ធ្វើការវិភាគប្រេងឥន្ធនៈ (សម្រាប់ការនាំចូល និងទីផ្សារ) ។

- កសាង និងអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញគ្រប់គ្រង ជំនាញឯកទេសដល់មន្ត្រី ដោយកំណត់

អគ្គសញ្ញាណមន្ត្រីជាក្រុម ឬជាបុគ្គល ដើម្បីមានលទ្ធភាពក្នុងការអនុវត្តន៍ការងារជាលក្ខណៈក្រុម (បណ្តុះបណ្តាលផ្ទៃក្នុង និងតាមជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ ឬអង្គការអន្តរជាតិ) ។

- កសាងខ្លឹមសារកម្មវិធី និងដំណើរការអនុវត្ត ការលើកកម្ពស់ការយល់ដឹងសាធារណៈ នៅតាមទីសាធារណៈ សាលារៀន និងបណ្តាញព័ត៌មាននានា ។

ថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល**

**ម៉ក់ ពេជ្ររិទ្ធ**

*កន្លែងទទួល*

- -ខុទ្ទកាល័យ **ឯកឧត្តមរដ្ឋមន្ត្រី**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- -អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- -អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
- -អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- -អគ្គាធិការដ្ឋាន
- -ឯកសារ-កាលប្បវត្តិ